ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និងឈ្មោះសំណុំរឿង : ១០៣/០៨ — ទីទ៉ានីណូ**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៨**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

១-ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន ទីទ៉ានីណូ ឌីសាញ (ខេមបូឌា) ហ្គាមេន ភីធីអ៊ី អិលធីឌី

អាសយដ្ឋាន : ផ្លូវអន្តរជាតិ ក្រុម០៣ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០៨៩ ៧៧៦ ២៥៣ ទូរសារលេខ : គ្មាន

តំណាងភាគីនិយោជក :

លោក នុត ប៊ុនសាការិយា ប្រធានរដ្ឋបាល

២- ភាគីកម្មករនិយោជិត

ឈ្មោះ : **សហព័ន្ធសហជីព-សហជីពឧម្មាធិបតេយ្យ នៃរោងចក្រ ទីទ៉ានីណូ**

អាសយដ្ឋាន : ផ្ទះលេខ ០៧ ផ្សារធំថ្មីព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៩៤១ ៦៦២ ទូរសារ : គ្មាន



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិត :

| | |
|---|---|
| ១- លោក ងួន ប៊ុនណារិទ្ធ | អនុប្រធានសហព័ន្ធសហជីព ធម្មាធិបតេយ្យ |
| ២- លោក ហ៊ួ ណារិទ្ធ | អគ្គលេខាធិការសហព័ន្ធសហជីព ធម្មាធិបតេយ្យ |
| ៣- លោក នេត ណាយ៉ែន | មន្ត្រីសហព័ន្ធសហជីព ធម្មាធិបតេយ្យ |
| ៤- លោក ស ចាន់ធី | ប្រធានសហជីព ធម្មាធិបតេយ្យ នៃរោងចក្រ វីវ៉ាទីណូ |
| ៥- លោក ស សុខលី | អនុប្រធានសហជីព ធម្មាធិបតេយ្យ នៃរោងចក្រ វីវ៉ាទីណូ |
| ៦- លោក យ៉ង សុភា | លេខាសហជីព ធម្មាធិបតេយ្យ នៃរោងចក្រ វីវ៉ាទីណូ |
| ៧- អៀង ម៉ារា | កម្មករ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតសុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ ៥ ដុល្លារ ឡើងវិញ(គឺចាប់ពីថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៨ បានផ្តល់ឱ្យកម្មករ) ។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចផ្តល់ជូនបានឡើយ គឺក្រុមហ៊ុនអនុវត្តតាមការព្រមព្រៀងដែលបានធ្វើកន្លងមកជាមួយកម្មករនិយោជិតនៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៨ ។

២- កម្មករនិយោជិតស្នើឱ្យក្រុមហ៊ុនផ្តល់ប្រាក់ចំនួន ២០ ដុល្លារ ក្នុងមួយខែសម្រាប់ថ្លៃទឹកដោះគោ ជំនួសឱ្យការសាងសង់បន្ទប់ទារកដ្ឋាន ។ ដោយឡែកភាគីក្រុមហ៊ុនមិនឯកភាពផ្តល់ជូនបានទេ គឺក្រុមហ៊ុនបានផ្តល់ចំនួន ៥ ដុល្លារ រួចហើយក្នុងមួយខែ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី ១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពគ្នាលើដំណោះស្រាយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៨៤៩ ក.ប/អក/វ.ក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៨ ។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :**

- លើកទី ១ នៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៨ (វេលាម៉ោង ០៨:៣០ នាទីព្រឹក
- លើកទី២ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៨ (វេលាម៉ោង ១៤:០០នាទី ដល់ម៉ោង ១៧:៣០នាទី)

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៨ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពធម្មាធិបតេយ្យ ទាមទារឱ្យក្រុមហ៊ុនកែលំអរលក្ខខ័ណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរឡើង។ បន្ទាប់មក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមជាបន្តបន្ទាប់ និងធ្វើផ្សះផ្សាចុងក្រោយ នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៨ ដោយបានទទួលលទ្ធផលសះជានឹងគ្នាចំនួន ០៣ ចំណុច លើការទាមទារចំនួន ០៥ ចំណុច។ ចំណុចមិនសះជាចំនួន ០២ ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៨។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតប្រចាំរោងចក្រ មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០២ ចំណុចនេះ ចំនួនពីរលើក ដូចបានរៀបរាប់ក្នុងកាលបរិច្ឆេទខាងលើ។

ថ្ងៃសវនាការលើកទី១ នៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៨ (វេលាម៉ោង ០៨:៣០ នាទីព្រឹក ត្រូវបានលើកដោយមានការស្នើសុំពីភាគីក្រុមហ៊ុន និងមានការឯកភាពពីភាគីកម្មករនិយោជិត និងពីក្រុមប្រឹក្សាអាជ្ញាកណ្តាល និងថ្ងៃសវនាការលើកទី២ នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៨ វេលាម៉ោង ១៤:០០នាទី រសៀល ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០២ ចំណុចនេះបន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ដូច្នេះក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងដោះស្រាយ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម:

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

## ឯកសារ ឧត្ថុតាង ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក-ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតផ្ទេរសិទ្ធិជូន លោក នុត ប៊ុនសាការិយា ប្រធានរដ្ឋបាល មានសិទ្ធិ និងអំណាចពេញលេញក្នុងការដោះស្រាយវិវាទការងារ ក្នុងនាមតំណាងម្ចាស់ក្រុមហ៊ុន ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៨។

២- លិខិតស្នើសុំពន្យាពេលចូលរួមសវនាការ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៨។

៣- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម របស់ក្រុមហ៊ុន វីវ៉ាធីណូ ឌីសាញ លេខ ៤៨២ ពណ.នគក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០០។

៤- ប័ណ្ណប៉ាតង់ របស់ក្រុមហ៊ុន វីវ៉ាធីណូ ឌីសាញ លេខ LTU . 019942 . 2008 ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៨។

៥- សំណើរសុំចុះទិដ្ឋាការលើបទបញ្ជាផ្ទៃក្នុង និងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន វីវ៉ាធីណូ ឌីសាញ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០០។

៦- កំណត់ហេតុនៃកិច្ចប្រជុំពិភាក្សាការងារ ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៨។

៧- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ក្រុមហ៊ុន វីវ៉ាធីណូ ឌីសាញ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៨។

៨- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ក្រុមហ៊ុន វីវ៉ាធីណូ ឌីសាញ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៨។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :

១- វិញ្ញាបនប័ត្រចុះបញ្ជិកា របស់សហជីព ធម្មាធិបតេយ្យ នៃរោងចក្រ វីវ៉ាធីណូ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៤ ។

២- សេចក្តីជូនដំណឹងរបស់ក្រុមហ៊ុន លេខ No HR/0027/03/08 ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៨។

៣- សេចក្តីថ្លែងការរបស់គណៈកម្មការប្រឹក្សាការងារ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៨។

៤- លក្ខន្តិកៈរបស់ សហជីពធម្មាធិបតេយ្យ នៃរោងចក្រ វីវ៉ាធីណូ លេខ ៦៦៣ ក.ប.វ/អក ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៤ ។

៥- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ក្រុមហ៊ុន វីវ៉ាធីណូ ឌីសាញ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៨។

THE ARBITRATION COUNCIL

៦- លិខិតលេខ ១២៩១ ក.ក.ប.វ/អក/វក. ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី ចុះថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៦។

៧- បង្កាន់ដៃទទួលសំណុំរឿង ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៨។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន វីវ៉ាទីណូ លេខ ៨៤៩ ក.ប/អក/ វ.ក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ ។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួម ក្រុមហ៊ុន វីវ៉ាទីណូ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៨។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី១ លេខ ៥២១ កប/អក/លកអ. ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៨ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី១ លេខ ៥២២ កប/អក/លកអ. ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៨។

៣- លិខិតរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការសម្រេចពន្យាពេលសវនាការ និងកំណត់កាលបរិច្ឆេទសវនាការលើកទី២ លេខ ០០៣/០៨ កបអ. ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៨។

**អនុលោម**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន វីវ៉ាទីណូ បានដំណើរការរបស់ខ្លួននៅឆ្នាំ ២០០០។ បច្ចុប្បន្ន មានជួលកម្មករនិយោជិត ចំនួនប្រហែល ១២០០ នាក់។
- នៅក្នុងក្រុមហ៊ុន វីវ៉ាទីណូ មានសហជីពចំនួន ៥ គឺ(១)-សហជីពធម្មាធិបតេយ្យ (២)-សហជីពសេរីកម្មករ (៣)-សហជីពកម្មករកម្ពុជា (៤)-សហជីពលើកតម្កើងជីវភាពកម្មករកម្ពុជា (៥)-សហជីពឧស្សាហកម្ម។
- សហជីពធម្មាធិបតេយ្យ នៃក្រុមហ៊ុន វីវ៉ាទីណូ ជាភាគីដើមបណ្តឹងក្នុងសំណុំរឿងនេះ។ សហជីពធម្មាធិបតេយ្យ មានសមាជិកចំនួន ប្រហែល ១០០ នាក់។

**ចំណុចវិវាទទី១ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន ផ្តល់ប្រាក់ឈ្នួលបន្ថែមចំនួន ៥ ដុល្លារអាមេរិក ដែលក្រុមហ៊ុនបានជូនដំណឹងផ្តល់ជូន នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៨ ដាច់ដោយឡែកពីសេចក្តីថ្លែងការណ៍របស់គណៈកម្មការប្រឹក្សាការងារ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៨ ឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម ៦ ដុល្លារអាមេរិក ដល់កម្មករនិយោជិត**

- នៅដើមខែមីនា តំណាងកម្មករនិយោជិត បានចរចារជាមួយក្រុមហ៊ុន ដើម្បីសុំឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលដល់កម្មករនិយោជិត ដោយមូលហេតុទំនិញទីផ្សារគ្រប់ប្រភេទឡើងថ្លៃ។
- នៅក្នុងពេលនោះដែរ សហព័ន្ធសហជីព សហជីពមូលដ្ឋាននៅតាមរោងចក្រនានា ក៏បានស្នើសុំទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្នើទៅរាជរដ្ឋាភិបាល ដើម្បីតម្លើងប្រាក់ឈ្នួលដល់កម្មករនិយោជិត ដោយមូលហេតុ ទំនិញទីផ្សារឡើងថ្លៃដែរ។
- នៅថ្ងៃទី ២៧ ខែ មីនា ឆ្នា ២០០៨ ក្រុមហ៊ុនបានចេញសេចក្តីជូនដំណឹងដល់កម្មករនិយោជិត នៃរោងចក្រថា ចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ តទៅ ក្រុមហ៊ុននឹងបូកបន្ថែម ៥ ដុល្លារ លើប្រាក់ឈ្នួលគោល សម្រាប់កម្មករនិយោជិតទាំងអស់ដែលចូលធ្វើការដំបូង ឬពេញសិទ្ធិ។ ប៉ុន្តែ ក្រុមហ៊ុនមិនទាន់បានអនុវត្តនូវសេចក្តីជូនដំណឹងរបស់ខ្លួនទេ មានន័យថា ក្រុមហ៊ុនមិនទាន់បានផ្តល់ប្រាក់ឈ្នួលបូកបន្ថែមចំនួន ៥ ដុល្លារអាមេរិក ឱ្យកម្មករនិយោជិតនៅឡើយទេ។
- នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៨ ដោយគោរពតាមអនុសាសន៍ ជាគោលការណ៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា គណៈកម្មការប្រឹក្សាការងារបានចេញសេចក្តីថ្លែងការត្រង់ចំណុចទី១ ថែងថា *"ផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់ទ្រទ្រង់ជីវភាពកម្មករនិយោជិតទាំងអស់ ដែលធ្វើការនៅរោងចក្រ សហគ្រាស គ្រឹះស្ថាន វាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង ក្នុងម្នាក់ៗ ចំនួន ៦ ដុល្លារសហរដ្ឋអាមេរិក ក្នុង១ខែ។ .........."*
- នៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៨ ក្រុមហ៊ុនបានកោះប្រជុំ ដោយបានអញ្ជើញមន្ត្រីជំនាញពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសហជីព កម្មករនិយោជិត ដើម្បីដោះស្រាយការផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៦ ដុល្លារអាមេរិក ក្នុងមួយខែ ដែលក្រុមហ៊ុនបានចេញប្រកាស ផ្តល់ប្រាក់ឈ្នួលបន្ថែមចំនួន ៥ ដុល្លារអាមេរិកមុន គឺក្រុមហ៊ុនមានកំហុសបច្ចេកទេសដោយទទួលព័ត៌មានខុស។ ជាលទ្ធផលដូចដែលមាននៅក្នុងកំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមត្រង់ចំណុចព្រមព្រៀងរបស់គូភាគីថែងថា *"កម្មករនិយោជិតឯកភាពតាមសេចក្តីជូនដំណឹងរបស់ក្រុមហ៊ុន ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៨ ដោយបងប្អូនឯកភាពទទួលយកប្រាក់ឈ្នួលគោលបន្ថែមចំនួន ៦ ដុល្លារអាមេរិក ដោយបូកបន្ថែមទៅលើប្រាក់ឈ្នួលគោលចាស់មុន ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៨។ ចំពោះប្រាក់ឈ្នួលគោល*

*បន្ថែមចំនួន ៦ ដុល្លារអាមេរិក នេះមានន័យថា ក្រុមហ៊ុនយកប្រាក់ឧបត្ថម្ភ បន្ថែម ៦ ដុល្លារអាមេរិក ដោយយោងទៅតាមសេចក្តីថ្លែងការរបស់គណៈកម្មការប្រឹក្សាការងារ ចុះ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៨ ប្តូរទៅជាប្រាក់ខែគោលវិញ។ ចំពោះការតម្លើងប្រាក់ខែគោលចំនួន ៥ ដុល្លារអាមេរិក កាលពីថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៨ គឺក្រុម ហ៊ុនមានកំហុសបច្ចេកទេស ដោយទទួលព័ត៌មានខុស"។*
ប៉ុន្តែ កិច្ចព្រមព្រៀងនេះ លោកប្រធាន សហជីពធម្មាធិបតេយ្យ មិនបានយល់ព្រមចុះហត្ថលេខាទេ។

- ភាគីក្រុមហ៊ុនបានបញ្ជាក់នៅក្នុងសវនាការថា ក្រុមហ៊ុនបានសុំទោសដោយផ្ទាល់មាត់ នូវកំហុសបច្ចេកទេសរបស់ក្រុមហ៊ុន នៅក្នុងពេលប្រជុំ ទើបឈានទៅដល់ការព្រមព្រៀងខាងលើនេះ។ ភាគីសហជីពកម្មករនិយោជិតយល់ស្របនឹងការលើកឡើងរបស់ក្រុមហ៊ុន។
- ភាគីក្រុមហ៊ុនបានបញ្ជាក់បន្ថែមថា សព្វថ្ងៃនេះ កម្មករនិយោជិតបានមកបើកប្រាក់ខែ នៅថ្ងៃទី ៧ រៀងរាល់ខែ ដោយក្រុមហ៊ុនបានដាក់បញ្ចូលប្រាក់ឧបត្ថម្ភបន្ថែមចំនួន ៦ ដុល្លារអាមេរិក ដោយបូកបន្ថែមទៅក្នុងប្រាក់ឈ្នួលគោល ដោយមិនមានកម្មករនិយោជិតណាម្នាក់ជំទាស់មិនបើកប្រាក់ខែឡើយ។ ភាគីសហជីព កម្មករនិយោជិតមិនជំទាស់នឹងការលើកឡើងរបស់ក្រុមហ៊ុនទេ។
- ភាគីសហជីព កម្មករនិយោជិតបានបញ្ជាក់នៅក្នុងសវនាការថា សហជីពមិនព្រមចុះហត្ថលេខាលើកិច្ចព្រមព្រៀងខាងលើនេះ មានន័យថា មិនព្រមអនុវត្តកិច្ចព្រមព្រៀងទេ។ ហេតុនេះហើយសហជីពនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលបន្ថែមចំនួន ៥ ដុល្លារអាមេរិក ដាច់ដោយឡែកពីប្រាក់ឧបត្ថម្ភបន្ថែម ៦ ដុល្លារអាមេរិក។

ចំណុចវិវាទទី២ : កម្មករនិយោជិតស្នើឱ្យក្រុមហ៊ុនផ្តល់ប្រាក់ចំនួន ២០ ដុល្លារក្នុងមួយខែ សម្រាប់ថ្លៃទឹកដោះគោជំនួសឱ្យការសាងសង់បន្ទប់ទារកដ្ឋាន

- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ចំនួន ២០ ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់ថ្លៃទឹកដោះគោ ជំនួសឱ្យការសាងសង់ទារកដ្ឋាន បើក្រុមហ៊ុនពុំអាចសង់ទាករដ្ឋានបានទេ។
- ភាគីកម្មករនិយោជិត បានបញ្ជាក់នៅក្នុងសវនាការថា មូលហេតុដែលកម្មករនិយោជិត ធ្វើការទាមទារនេះ ដោយហេតុថា ទំនិញនៅទីផ្សារឡើងថ្លៃ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ បើក្រុមហ៊ុនមិនអាចផ្តល់ជូន ២០ ដុល្លារអាមេរិកបានទេ ក្រុមហ៊ុនអាចផ្តល់ជូនលើសពី ៥ ដុល្លារអាមេរិក ព្រោះកន្លងមកក្រុមហ៊ុនផ្តល់តែ ០៥ ដុល្លារអាមេរិកប៉ុណ្ណោះ។
- ភាគីក្រុមហ៊ុនបានបញ្ជាក់នៅក្នុងសវនាការថា លោកបានមកបំរើការងារឱ្យក្រុមហ៊ុនជាអ្នកគ្រប់គ្រងរដ្ឋបាលនៅចុងឆ្នាំ២០០៧។ ហេតុនេះ លោកមិនដឹងថា ក្រុមហ៊ុនបានផ្តល់ប្រាក់ចំនួន ៥ ដុល្លារអាមេរិកក្នុងមួយខែសម្រាប់ថ្លៃទឹកដោះគោជំនួសការសង់ទារកដ្ឋាន ចាប់តាំងពីឆ្នាំ [illegible]

ជិតសុំឱ្យក្រុមហ៊ុនតម្លើងប្រាក់សម្រាប់ថ្លៃទឹកដោះគោ ជំនួសការសង់ទារកដ្ឋាននេះ ក្រុមហ៊ុនមិនអាចតម្លើងជូនបានទេ។

- ភាគីកម្មករនិយោជិតបានបញ្ជាក់បន្ថែមថា ប្រាក់ចំនួន ៥ ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់ថ្លៃទឹកដោះគោមិនគ្រប់គ្រាន់ទេ ហើយយកកូនទៅឱ្យគេមើលនៅខាងក្រៅ ក៏មិនគ្រប់គ្រាន់ដែរ។ ប៉ុន្តែទោះបីយ៉ាងណា បើក្រុមហ៊ុនអនុវត្តទៅតាមច្បាប់ស្ដីពីការងារ សង់ទារកដ្ឋាននៅក្នុងក្រុមហ៊ុន ដើម្បីឱ្យកម្មករនិយោជិតយកកូនទៅផ្ញើ កម្មករនិយោជិតមិនធ្វើការទាមទារឱ្យក្រុមហ៊ុនផ្ដល់ប្រាក់សម្រាប់ថ្លៃទឹកដោះគោទៀតទេ។

## ហេតុផលនៃសេចក្ដីសម្រេច

**ចំណុចវិវាទទី១ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន ផ្ដល់ប្រាក់ឈ្នួលបន្ថែមចំនួន ៥ ដុល្លារអាមេរិក ដែលក្រុមហ៊ុនបានជូនដំណឹងផ្ដល់ជូន នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៨ ដាច់ដោយឡែកពីសេចក្ដីថ្លែងការណ៍របស់គណៈកម្មការប្រឹក្សាការងារ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៨ ឱ្យក្រុមហ៊ុនផ្ដល់ប្រាក់ឧបត្ថម្ភបន្ថែម ៦ ដុល្លារអាមេរិក ដល់កម្មករនិយោជិត**

ផ្អែកតាមចំណុចនៃការរកឃើញនៃអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានរកឃើញថា ក្រុមហ៊ុនបានចេញសេចក្ដីជូនដំណឹងដល់កម្មករនិយោជិត នៃរោងចក្រ នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៨ ថា ចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ តទៅ ក្រុមហ៊ុននឹងបូកបន្ថែម ៥ ដុល្លារអាមេរិក លើប្រាក់ឈ្នួលគោលសម្រាប់កម្មករនិយោជិតទាំងអស់ដែលធ្លាប់ធ្វើការដំបូង ឬពេញសិទ្ធិ គឺក្រុមហ៊ុនជួយសម្រួលដល់ការលំបាកលើជីវភាពរបស់កម្មករនិយោជិត ពីព្រោះទំនិញទីផ្សារឡើងថ្លៃ។ ភាគីសហជីព កម្មករនិយោជិត ក៏បានឯកភាព និងទទួលស្គាល់ដែរថាក្រុមហ៊ុនសហការល្អជាមួយកម្មករនិយោជិត និងបានដឹងអំពីការលំបាករបស់កម្មករនិយោជិត។ ហេតុនេះហើយក្រុមហ៊ុនបានផ្ដល់ប្រាក់ចំនួន ៥ ដុល្លារអាមេរិក បន្ថែមលើប្រាក់ឈ្នួលគោលមុនពេល ដែលគណៈកម្មការប្រឹក្សាការងារ ចេញសេចក្ដីថ្លែងការណ៍។ ក្នុងចន្លោះពេលប្រហែលតែមួយសប្ដាហ៍ គណៈកម្មការប្រឹក្សាការងារបានចេញសេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៨ ត្រង់ចំណុចទី១ ចែងថា *" ផ្ដល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់ទ្រទ្រង់ជីវភាពកម្មករនិយោជិតទាំងអស់ ដែលធ្វើការនៅរោងចក្រ សហគ្រាស គ្រឹះស្ថាន វាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើងក្នុងម្នាក់ៗ ចំនួន ៦ ដុល្លារសហរដ្ឋអាមេរិកក្នុង១ខែ។"* បន្ទាប់ពីទទួលបាននូវសេចក្ដីថ្លែងការរបស់ *គណៈកម្មការប្រឹក្សាការងារ* ក្រុមហ៊ុនបានធ្វើការដោះស្រាយភ្លាមៗ ជាមួយកម្មករនិយោជិត គឺក្រុមហ៊ុនបានកោះប្រជុំ ដោយបានអញ្ជើញមន្ត្រីជំនាញពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងសហជីព កម្មករនិយោជិត ដើម្បីដោះស្រាយការផ្ដល់ប្រាក់ឧបត្ថម្ភចំនួន ៦ ដុល្លារអាមេរិក ក្នុងមួយខែ ដែលគណៈកម្មការប្រឹក្សាការងារបានចេញសេចក្ដីថ្លែងការនេះ និងប្រាក់ឈ្នួលបន្ថែមចំនួន ៥ ដុល្លារអាមេរិក ដែលក្រុមហ៊ុនបានចេញប្រកាសមុន គឺក្រុមហ៊ុន

មានកំហុសបច្ចេកទេស ដោយទទួលព័ត៌មានខុស ហើយក្រុមហ៊ុនបានសម្រួលដាក់បញ្ចូលប្រាក់ឧបត្ថម្ភបន្ថែម ចំនួន ៦ ដុល្លារអាមេរិក ដោយបូកបន្ថែមទៅក្នុងប្រាក់ឈ្នួលគោល ។ កម្មករនិយោជិតនៅក្នុងសំណុំរឿងនេះ ក៏ទទួលស្គាល់ថា ក្រុមហ៊ុនពិតជាបានកោះប្រជុំ និងធ្វើការសុំទោសចំពោះកំហុសដែលទទួលបាននូវពត៌មានខុសនេះមែន ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា គោលបំណងនៃការផ្តល់ប្រាក់បន្ថែមដល់កម្មករនិយោជិត គឺដើម្បីសម្រួលដល់ទំនិញទីផ្សារឡើងថ្លៃ។ ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ក្រុមហ៊ុននៅពេលធ្វើការប្រកាសពីប្រាក់ឧបត្ថម្ភ ៥ ដុល្លារអាមេរិកនោះ គឺមានការភាន់ច្រឡំពិតមែន ដោយក្រុមហ៊ុនបានធ្វើការកោះប្រជុំ ដើម្បីជូនដំណឹងពីការភាន់ច្រលំរបស់ខ្លួន។ ហេតុនេះប្រសិនបើ ឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលបន្ថែមចំនួន ៥ ដុល្លារអាមេរិក ដាច់ដោយឡែកពីសេចក្តីថ្លែងការរបស់គណៈកម្មការប្រឹក្សាការងារ គឺជាការដាក់បន្ទុកដល់ក្រុមហ៊ុន ហើយដែលជាការមិនសមហេតុសមផលទេ។

លើសពីនេះទៀត ភាគីកម្មករនិយោជិត បានឯកភាពទទួលស្គាល់ថា កម្មករនិយោជិតទាំងអស់បានមកបើកប្រាក់ខែ នៅថ្ងៃទី ៧ ជារៀងរាល់ខែ ដែលក្រុមហ៊ុនបានដាក់បញ្ចូលប្រាក់ឧបត្ថម្ភបន្ថែមចំនួន ៦ ដុល្លារអាមេរិក បូកបន្ថែមទៅក្នុងប្រាក់ឈ្នួលគោល មិនមានកម្មករនិយោជិតណាម្នាក់ជំទាស់មិនបើកប្រាក់ខែទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើថា ក្រុមហ៊ុនមានហេតុផល សមហេតុសមផល ក្នុងការមិនផ្តល់ប្រាក់បន្ថែមចំនួន ៥ ដុល្លារអាមេរិក ដែលក្រុមហ៊ុនបានចេញប្រកាស។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់កម្មករនិយោជិតឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលបន្ថែមចំនួន ៥ ដុល្លារអាមេរិក ដែលក្រុមហ៊ុនបានជូនដំណឹង នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៨ ដាច់ដោយឡែកពីសេចក្តីថ្លែងការរបស់គណៈកម្មការប្រឹក្សាការងារ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៨ ឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម ៦ ដុល្លារអាមេរិក ដល់កម្មករនិយោជិត មិនត្រឹមត្រូវទេ ពីព្រោះមូលហេតុនៃការផ្តល់ប្រាក់បន្ថែមនេះ គឺមកពីទំនិញទីផ្សារឡើងថ្លៃតែមួយដូចគ្នា ។

**ចំណុចវិវាទទី២ : កម្មករនិយោជិតស្នើឱ្យក្រុមហ៊ុនផ្តល់ប្រាក់ចំនួន ២០ ដុល្លារក្នុងមួយខែ សម្រាប់ថ្លៃទឹកដោះគោ ជំនួសឱ្យការសាងសង់បន្ទប់ទារកដ្ឋាន**

ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ចំនួន ២០ ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់ថ្លៃទឹកដោះគោ ជំនួសឱ្យការសាងសង់ទារកដ្ឋាន ដោយលើកហេតុផលថា កន្លងមកក្រុមហ៊ុនបានផ្តល់ឱ្យតែ ៥ ដុល្លារអាមេរិកក្នុងមួយខែ មិនគ្រប់គ្រាន់ ពីព្រោះទំនិញទីផ្សារឡើងថ្លៃ ហើយម្យ៉ាងទៀត បើយកកូនទៅឱ្យគេមើលនៅខាងក្រៅក៏មិនគ្រប់គ្រាន់ដែរ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើក្រុមហ៊ុនមានកាតព្វកិច្ចសង់ទារកដ្ឋានដែរ ឬទេ តាមច្បាប់ស្តីពីការងារ? តើក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ចំនួន ៥ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់ថ្លៃទឹកដោះគោជំនួសការសង់ទារកដ្ឋានកន្លងមក មានសុពលភាពអនុវត្តដែរ ឬទេ តាមច្បាប់ស្តីពីការងារ?

**តើក្រុមហ៊ុនមានកាតព្វកិច្ចសង់ទារកដ្ឋានដែរ ឬទេ តាមច្បាប់ស្តីពីការងារ?**

មាត្រា១៨៦ នៃច្បាប់ស្តីពីការងារចែងថា" *នាយកសហគ្រាសទាំងឡាយ ដែលប្រើស្ត្រីចាស់ក្តី ក្មេងក្តីចំនួនយ៉ាងតិចមួយរយនាក់ ត្រូវរៀបចំបន្ទប់សម្រាប់បំបៅកូនមួយនៅក្នុង ឬនៅជិតនោះ ហើយនឹងទារកដ្ឋានមួយផង ។*

*ក្នុងករណីដែលសហគ្រាសពុំមានលទ្ធភាពរៀបចំទារកដ្ឋានសម្រាប់ទទួលកុមារអាយុលើសពីដប់ប្រាំបីខែផ្ទាល់បានទេ នារីជាកម្មករនិយោជិតអាចផ្ញើកូនរបស់ខ្លួននៅទារកដ្ឋានណាមួយ ដោយនិយោជកជាអ្នកចេញសោហ៊ុយថែរក្សាទារកនោះ ។* "

ផ្អែកតាមខ្លឹមសារនៃមាត្រាខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចត្រូវសង់ទារកដ្ឋាន។ ម្យ៉ាងវិញទៀត នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកដែលមានជួលកម្មករនិយោជិតស្ត្រីយ៉ាងតិច ១០០ នាក់ មានកាតព្វកិច្ចត្រូវសង់ទារកដ្ឋានមួយ បើនិយោជកមិនមានលទ្ធភាពរៀបចំទារកដ្ឋានសំរាប់ទទួលកុមារអាយុលើសពី ១៨ ខែ ផ្ទាល់បានទេ នារីជាកម្មករនិយោជិតអាចផ្ញើកូនខ្លួននៅទារកដ្ឋានខាងក្រៅបាន ដោយនិយោជកជាអ្នកចេញសោហ៊ុយថែទាំទារកតាមវិក័យប័ត្រ ដែលបង់ប្រាក់សម្រាប់ប្រើប្រាស់ទារកដ្ឋានខាងក្រៅ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦៣/០៤-សាញវែល ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២ និងលេខ ៦៨/០៤-ស៊ុធីញូ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១) ។

នៅក្នុងករណីនេះ ភាគីទាំងពីរមិនមានវិវាទទាក់ទងនឹងការផ្ញើកូននៅខាងក្រៅទេ។ ប៉ុន្តែ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ ២០ ដុល្លារអាមេរិក ជំនួសការសង់ទារកដ្ឋាន។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ជំនួសការសង់ទារកដ្ឋាន គឺ ជាការទាមទារផ្ទុយនឹងច្បាប់ស្តីពីការងារ។ ប៉ុន្តែកម្មករនិយោជិត បញ្ជាក់ទៀតថា បើក្រុមហ៊ុនអនុវត្តទៅតាមច្បាប់ស្តីពីការងារ មាត្រា ១៨៦ សង់ទារកដ្ឋាន នៅក្នុងក្រុមហ៊ុន ដើម្បីឱ្យកម្មករនិយោជិតយកកូនទៅផ្ញើ កម្មករនិយោជិតមិនធ្វើការទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់សម្រាប់ថ្លៃទឹកដោះគោទៀតទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ក្រុមហ៊ុនមិនមានទារកដ្ឋានទេ ហើយសព្វថ្ងៃក្រុមហ៊ុនបានផ្តល់ប្រាក់ ៥ ដុល្លារអាមេរិក ជំនួសវិញ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបន្តធ្វើការពិចារណាថា ***តើក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ចំនួន ៥ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់ថ្លៃទឹកដោះគោ ជំនួសការសង់ទារកដ្ឋានកន្លងមក មានសុពលភាពអនុវត្ត ដែរ ឬទេ តាមច្បាប់ស្តីពីការងារ?***

ពាក់ព័ន្ធនឹងការព្រមព្រៀង ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិត និងសហជីព ដែលមានសិទ្ធិតំណាងឱ្យសមាជិករបស់ខ្លួន មានសិទ្ធិព្រមព្រៀង ឬចុះកិច្ចព្រមព្រៀង ទោះបីកិច្ចព្រមព្រៀងនោះមាន

THE ARBITRATION COUNCIL

លក្ខខ័ណ្ឌខ្ពស់ជាង ឬទាបជាងច្បាប់ស្តីពីការងារក៏ដោយ ហើយកិច្ចព្រមព្រៀងនោះ ត្រូវបានយកមកពិនិត្យ និងដោះស្រាយនៅពេលមានវិវាទកើតឡើង ឬនៅពេលភាគីវិវាទបានលើកឡើង។

មាត្រា១៣ នៃច្បាប់ស្តីពីការងារចែងថា " *បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ការងារនេះ មានលក្ខណៈជាសេចក្តីបង្គាប់ជាសាធារណៈ វៀរលែងតែមានបដិប្បញ្ញត្តិបញ្ជាក់ច្បាស់។ ដូច្នេះវិធានទាំងអស់ដែលកើតឡើងដោយការសម្រេចចិត្តជាឯកតោភាគីក្តី ដោយកិច្ចសន្យា ឬអនុសញ្ញាណាមួយក្តី ដែលមិនគោរពបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ឬដែលមិនគោរពអត្ថបទទាំងឡាយដែលណែនាំឱ្យអនុវត្តច្បាប់នេះ ត្រូវទុកជាមោឃៈ ដោយពេញច្បាប់។...* "

ក្រុមប្រឹក្សាអាជ្ញាកណ្តាល យល់ឃើញថា គោលបំណងនៃច្បាប់ស្តីពីការងារដែលតម្រូវឱ្យក្រុមហ៊ុនសង់ទារកដ្ឋាន គឺដើម្បីបង្ករលក្ខណៈឱ្យម្តាយ និងកូនបាននៅជិតគ្នា ផ្តល់ភាពកក់ក្តៅដល់កូន បានបំបៅដោះកូនដោយធម្មជាតិ ដោយមិនប្រើប្រាស់ទឹកដោះគោក្នុងកំឡុងពេលប្រាំមួយខែដំបូង ដូចដែលគោលនយោបាយរាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើការផ្សព្វផ្សាយ និងរក្សាសុវត្ថិភាពកូននៅពេលម្តាយកំពុងបំពេញការងារ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៧៧/០៨-ស៊ីង តាយ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៣)* ។

ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ថ្វីត្បិតតែក្រុមហ៊ុន និងសហជីពយល់ព្រមទទួលយកប្រាក់ជំនួសថ្លៃសង់ទារកដ្ឋាន ប៉ុន្តែ ការទទួលយកប្រាក់ជំនួសថ្លៃសង់ទារកដ្ឋាននេះ មិនមានលក្ខណៈគ្រប់គ្រាន់តាមគោលបំណងច្បាប់ស្តីពីការងារទេ ហើយការផ្តល់ប្រាក់ជំនួសថ្លៃសង់ទារកដ្ឋាននេះ ក៏មិនអាចឱ្យនិយោជករួចផុតពីកាតព្វកិច្ចតាមច្បាប់ស្តីពីការងារ ក្នុងការសង់ទារកដ្ឋាននោះបានផងដែរ។ ក៏ប៉ុន្តែ និយោជកអាចមានជម្រើសក្នុងការផ្តល់ប្រាក់ជួសការសាងសង់ទារកដ្ឋាន នៅពេលដែលនិយោជកមិនមានលទ្ធភាពរៀបចំទារកដ្ឋានសម្រាប់ទទួលកុមារអាយុលើសពី ១៨ ខែផ្ទាល់បានទេ នារីជាកម្មករនិយោជិតអាចផ្ញើកូនខ្លួននៅទារកដ្ឋាន ខាងក្រៅបាន ដោយនិយោជកជាអ្នកចេញសោហ៊ុយថែទាំទារកតាមវិក័យប័ត្រ ដែលបង់ប្រាក់ សម្រាប់ប្រើប្រាស់ទារកដ្ឋានខាងក្រៅ។

ដូច្នេះ ជាសរុប ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់កម្មករឱ្យក្រុមហ៊ុនផ្តល់ប្រាក់ជំនួសថ្លៃសង់ទារកដ្ឋាន និងបង្គាប់ឱ្យក្រុមហ៊ុនសង់ទារកដ្ឋាន។ ក៏ប៉ុន្តែ ក្នុងកំឡុងពេលក្រុមហ៊ុន មិនទាន់សង់ទារកដ្ឋានរួច ក្រុមហ៊ុនអាចផ្តល់ប្រាក់ចំនួន ៥ ដុល្លារអាមេរិកក្នុងមួយខែ តាមការកិច្ចព្រមព្រៀងបាន។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅនេះ:

# សម្រេច និង បង្គាប់

**ចំណុចវិវាទទី១:** បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលបន្ថែមចំនួន ៥ ដុល្លារអាមេរិក ដែលក្រុមហ៊ុនបានជូនដំណឹងផ្តល់ជូន នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៨ ដាច់ដោយឡែកពីសេចក្តីថ្លែងការរបស់គណៈកម្មការប្រឹក្សាការងារ ឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម ៦ដុល្លារអាមេរិកក្នុងមួយខែ នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៨។

**ចំណុចវិវាទទី២:** - បដិសេធការទាមទាររបស់កម្មករនិយោជិតឱ្យក្រុមហ៊ុនផ្តល់ប្រាក់ជំនួសថ្លៃសង់ទារកដ្ឋាន។

-បង្គាប់ឱ្យក្រុមហ៊ុនសង់ទារកដ្ឋាន ហើយក្នុងកំឡុងពេល ក្រុមហ៊ុនមិនទាន់សង់ទារកដ្ឋានរួច ក្រុមហ៊ុនអាចផ្តល់ប្រាក់ចំនួន ៥ ដុល្លារអាមេរិកក្នុងមួយខែ តាមការកិច្ចព្រមព្រៀងបាន។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់ជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង បន្ទាប់ពីសេចក្តីបង្គាប់នេះចេញទៅ ដោយភាគីទាំងពីរបានយល់ព្រមជ្រើសរើសយកសេចក្តីបង្គាប់នេះ នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៨។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **អ៊ឹង សុន្ធី**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : លឹម សុទណ្ណា

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **ម៉ែន ម៉ុនឈា**

ហត្ថលេខា: ------------------------------